# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "កាតព្វកិច្ចពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ និងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធ អាជីវកម្មតាមអនឡាញ (E-Filing) ព្រមទាំងវិធានវិក្កយបត្រទម្រង់ថ្មី"

ថ្ងៃព្រហស្បតិ៍ ៤រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ត្រូវនឹង ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ សណ្ឋាគារ សុខាភ្នំពេញ ជ្រោយចង្វារ




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង ៨:០០នាទីព្រឹក ថ្ងៃព្រហស្បតិ៍ ៤រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី ១២ ខែមីនា ឆ្នាំ២០២០ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ និងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (E-Filing) ព្រមទាំងវិធានវិក្កយបត្រទម្រង់ថ្មី" ក្រោមអធិបតីភាពរបស់ ឯកឧត្តមបណ្ឌិត **ភែន សម្បត្តិ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ នៅសណ្ឋាគារ សុខាភ្នំពេញ ជ្រោយចង្វារ ដោយមានវត្តមានចូលរួមរបស់ថ្នាក់ដឹកនាំ និងមន្ត្រីពន្ធដារពាក់ព័ន្ធ ភ្នាក់ងារសេវាកម្មពន្ធដារ និងអភិបាល




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ឬអ្នកតំណាងសហគ្រាស សរុបប្រមាណជាង ១000 នាក់។

ជាកិច្ចចាប់ផ្ដើម ឯកឧត្តមបណ្ឌិត កែន សម្បត្តិ បានសំដែងនូវកិច្ចស្វាគមន៍ និងវាយតម្លៃខ្ពស់ ចំពោះវត្តមានលោកឧកញ៉ា លោក លោកស្រី នាងកញ្ញា ដែលបានឆ្លៀតពេលវេលាដ៏មមាញឹក និងមានតម្លៃរបស់ខ្លួន អញ្ជើញចូលរួមក្នុងសិក្ខាសាលា ដ៏មានសារៈសំខាន់ ញ៉ាំងឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ របស់អ្នកជាប់ពន្ធ ក្នុងការស្វែងយល់នូវបទប្បញ្ញត្តិស្ដីពីពន្ធដារ ក៏ដូចជាលិខិតបទដ្ឋានពាក់ព័ន្ធ ដើម្បីបានជាធាតុចូលយកទៅអនុវត្តបំពេញកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ។ ជាមួយគ្នានេះ ឯកឧត្តមបណ្ឌិត បានថ្លែងនូវមូលវិចារណ៍ដ៏ថ្លៃថ្លា ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យម នាយកដ្ឋានសវនកម្មសហគ្រាស និងនាយកដ្ឋាន-បច្ចេកវិទ្យាព័ត៌មាន ដែលបានដឹកនាំរៀបចំ និងសហការចាត់តំណាងចូលរួម ជាវាគ្មិនក្នុងអង្គសិក្ខាសាលានេះ។ ទន្ទឹមនឹងនេះ ឯកឧត្តមបណ្ឌិតបានលើកឡើងថា ការរៀបចំសិក្ខាសាលានេះឡើង គឺក្នុងគោលបំណងផ្សព្វផ្សាយអំពីវឌ្ឍនភាពការងារថ្មីៗ និងវិធានការនានាដែលបានដាក់ចេញ និងគ្រោងដាក់ឱ្យអនុវត្តនាពេលឆាប់ៗខាងមុខនេះ សំដៅពង្រឹងការផ្ដល់សេវាជូនអ្នកជាប់ពន្ធ ក៏ដូចជាឆ្លើយតបនឹងដំណោះស្រាយនូវបញ្ហាប្រឈមនានា។ ថ្មីៗនេះផងដែរ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានចេញប្រកាសលេខ ០៩៨ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ស្ដីពីពន្ធលើប្រាក់ចំណូល ហើយក៏បានធ្វើការកែសម្រួលនូវនីតិវិធីនៃការធ្វើសវនកម្មតាមរយៈប្រកាសលេខ ២៧០ សហវ.ប្រក ចុះថ្ងៃទី១៣ មីនា ឆ្នាំ២០១៩ ដោយមិនមានការចុះធ្វើសវនកម្មត្រួត ឬជាន់គ្នា ដោយរយៈពេលនៃឆ្នាំជាប់ពន្ធត្រូវចុះធ្វើសវនកម្មត្រូវបានកែសម្រួល និងកាត់បន្ថយ វៀរលែងតែមានករណីល្មើសធ្ងន់ធ្ងរ ការជ្រើសរើសសហគ្រាសធ្វើសវនកម្មដោយផ្អែក លើហានីភ័យ និងលក្ខណៈ វិនិច្ឆ័យច្បាស់លាស់ និងបន្ថយអត្រាការប្រាក់ពី ២% មកត្រឹម ១,៥%។ ការរៀបចំប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (E-Filing) ជួយសម្រួលដល់ការដាក់លិខិតប្រកាសពន្ធប្រចាំខែ ដោយអ្នកជាប់ពន្ធអាចបញ្ចូលបញ្ជីទិញ-លក់ ព័ត៌មាន ពន្ធកាត់ទុក ពន្ធលើប្រាក់បៀវត្សពន្ធលើអត្ថប្រយោជន៍បន្ថែម និងពន្ធ-អាករផ្សេងៗ តាមប្រព័ន្ធអនឡាញ ព្រមទាំងកាត់បន្ថយពេលវេលា និងការលំបាកក្នុងការបំពេញលិខិតប្រកាសដោយដៃ ជំនួសដោយការបោះពុម្ពរបាយការណ៍ប្រកាសពន្ធតាមប្រព័ន្ធអនឡាញ។ ការដាក់ឱ្យអនុវត្តនូវវិធានវិក្កយបត្រទម្រង់ថ្មី ដោយកំណត់ច្បាស់លាស់អំពីវិធី ឬបែបផែននៃការប្រើប្រាស់វិក្កយបត្រ ឱ្យបានត្រឹមត្រូវ ដើម្បីធានានូវប្រសិទ្ធភាព និងតម្លាភាពក្នុងការប្រមូលពន្ធ-អាករនានា ដោយអគ្គនាយកដ្ឋានពន្ធដារ បានចេញនូវសេចក្ដីជូនដំណឹងលេខ ៣២១៨ អពដ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ ស្ដីពីការអនុវត្តប្រកាសលេខ ៧២៣ សហវ.ប្រក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ស្ដីពីវិធាននៃការប្រើប្រាស់វិក្កយបត្រ។ ឯកឧត្តមបណ្ឌិតក៏បានបន្ថែមថា សិក្ខាសាលានាព្រឹកនេះ ត្រូវបានធ្វើឡើងក្នុងបរិបទនៃការកែទម្រង់ស៊ីជម្រៅ និងមុតស្រួចលើគ្រប់វិស័យរបស់រាជរដ្ឋាភិបាល និងជាពិសេសឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣ ដែលមានគោលបំណង ជាយុទ្ធសាស្ត្រចំនួន ០៣ គឺ **១) បង្កើនអនុលោមភាពតាមច្បាប់ដោយស្ម័គ្រចិត្ត និងកាត់បន្ថយជាអតិបរមា នូវបន្ទុកអ្នកជាប់ពន្ធ ដោយផ្ដល់សេវាប្រកបដោយគុណភាព ២)បន្តពង្រឹងការអនុវត្តច្បាប់ និងបទ**



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

**ប្បញ្ញត្តិស្តីពីពន្ធដារ ប្រកបដោយភាពទន់ភ្លន់ ម៉ឺងម៉ាត់ និងស្មើភាព ដើម្បីជំរុញអ្នកជាប់ពន្ធឱ្យបំពេញកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ និង៣) អនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយពង្រឹងស្ថាប័ន**។ឯកឧត្តមបណ្ឌិតក៏បានបញ្ជាក់បន្ថែមផងដែរថា ពន្ធគឺជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូបត្រូវបំពេញដោយខានមិនបាន គ្រាន់តែការបង់ពន្ធនោះត្រូវបំពេញ តាមប្រភេទពន្ធប្រយោល ឬតាមប្រភេទពន្ធផ្ទាល់តិចឬច្រើន ទៅតាមសកម្មភាព និងធុរកិច្ចរបស់អ្នកជាប់ពន្ធរៀងៗខ្លួន ដើម្បី ចូលរួមដល់ការចំណាយសាធារណៈរបស់ប្រទេស។ ដូច្នេះដើម្បីធ្វើឱ្យប្រទេសកម្ពុជាកាន់តែមានសន្ទុះរីកចម្រើនជឿនលឿនថែមទៀត ស្របតាមចក្ខុវិស័យ ដែលមានចែងក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ថានឹងប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់ ឬប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០ យើងទាំងអស់គ្នាត្រូវចូលរួមបង់ពន្ធឱ្យបានត្រឹមត្រូវ តាមបទប្បញ្ញត្តិច្បាប់ស្តីពីសារពើពន្ធ និងលិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន ហើយត្រូវចាត់ទុកថា ការបង់ពន្ធនេះ គឺជាការចូលរួមចំណែកដល់ការវិនិយោគសម្រាប់ខ្លួនយើងផ្ទាល់ សម្រាប់កូនចៅយើង និងសម្រាប់ការរីកចម្រើនរបស់ប្រទេសយើងទៅអនាគត។

ឯកឧត្តមបណ្ឌិតក៏បានលើកឡើងថា ដើម្បីធានាគណនេយ្យភាព អគ្គនាយកដ្ឋានពន្ធដារបានខិតខំធ្វើកំណែទម្រង់រដ្ឋបាលសារពើពន្ធ និងជាពិសេសការធ្វើទំនើបកម្មរដ្ឋបាលពន្ធដារ តាមរយៈការដាក់ចេញនូវកម្មវិធីបច្ចេកវិទ្យាជាច្រើន ក្នុងការគាំទ្រដល់ការប្រមូលចំណូលពន្ធដារនិងការគ្រប់គ្រងទិន្នន័យឱ្យបានច្បាស់លាស់ សំដៅពង្រឹងអភិបាលកិច្ចល្អ។ ឯកឧត្តមបណ្ឌិតសង្ឃឹម នឹងជឿជាក់យ៉ាងមុតមាំថា សិក្ខាកាមទាំងអស់នឹងយកចិត្តទុកដាក់ត្រងត្រាប់ស្តាប់នូវការពន្យល់ណែនាំរបស់វាគ្មិន ដើម្បីបានជាធាតុចូលសម្រាប់យកទៅអនុវត្តឱ្យបានត្រឹមត្រូវ តាមបទប្បញ្ញត្តិច្បាប់ស្តីពីសារពើពន្ធ និងលិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន។ ទន្ទឹមនឹងនេះ ឯកឧត្តមបណ្ឌិតបានគូសបញ្ជាក់ផងដែរថា ចំពោះស្ថានភាពអាជីវកម្មឆ្នាំ២០១៩ និងស្ថានភាពដើមឆ្នាំ២០២០ ដែលបណ្តាលមកពីការរីករាលដាល នៃជម្ងឺផ្លូវដង្ហើម Covid-19 សហគ្រាសត្រូវបែងចែកឱ្យដាច់ពីគ្នា ចំពោះស្ថានភាពអាជីវកម្ម ឆ្នាំ២០១៩ ជាឆ្នាំដែលកម្ពុជាមានកំណើនសេដ្ឋកិច្ច មានភាពរីកចម្រើន និងទទួលបានលទ្ធផលល្អប្រសើរ ដូចនេះត្រូវបំពេញកាតព្វកិច្ចពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៩ ដោយធ្វើការប្រកាស និងបង់ពន្ធឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ចៀសវាងទទួលរងនូវពិន័យ និងទោសទណ្ឌនានាជាយថាហេតុ។ អគ្គនាយកដ្ឋានពន្ធដារ មិនចង់ឃើញក្រុមហ៊ុនប្រកាសបង់ពន្ធមិនបានត្រឹមត្រូវ ហើយទទួលរងនូវការពិន័យទោសទណ្ឌពីមន្រ្តីសវនករពន្ធដារ ដែលធ្វើឱ្យអ្នកជាប់ពន្ធមិនសប្បាយចិត្តនោះទេ។ ដើម្បីចៀសវាងបាននូវស្ថានភាពបែបនេះ ក្រុមហ៊ុនត្រូវពង្រឹងអភិបាលកិច្ចល្អរបស់ក្រុមហ៊ុន។ អគ្គនាយកដ្ឋានពន្ធដារ បានខិតខំធ្វើកំណែទម្រង់រដ្ឋបាលសារពើពន្ធ និងជាពិសេស ការធ្វើទំនើបកម្មរដ្ឋបាលពន្ធដារតាមរយៈការដាក់ចេញនូវកម្មវិធីបច្ចេកវិទ្យាជាច្រើន ក្នុងការគាំទ្រដល់ការប្រមូលចំណូលពន្ធដារ និងការគ្រប់គ្រងទិន្នន័យឱ្យបានច្បាស់លាស់ សំដៅពង្រឹងអភិបាលកិច្ចល្អ។ ដូច្នេះ ដើម្បីធានាបាននូវស្ថានភាព ឈ្នះ-ឈ្នះ ក្នុងន័យរីករាយទាំងអស់គ្នា ត្រូវពង្រឹងអភិបាលកិច្ចទ្វេទិស គឺទាំងអគ្គនាយកដ្ឋានពន្ធដារ និងទាំងក្រុមហ៊ុន។

ឯកឧត្តមបណ្ឌិតក៏បានជំរុញ និងលើកទឹកចិត្តឱ្យសិក្ខាកាមទាំងអស់ ចូលរួមយ៉ាងសកម្មនៅក្នុងអង្គសិក្ខាសាលាពេញមួយ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ព្រឹក តាមរយៈការលើកជាមតិ យោបល់ និងសំណួរពាក់ព័ន្ធសំដៅប្រមូលបាននូវធាតុចូល ជាការយល់ដឹងនូវបទប្បញ្ញត្តិបទពិសោធន៍ សម្រាប់យកទៅអនុវត្តកាតព្វកិច្ចសារពើពន្ធឱ្យបានត្រឹមត្រូវ។ ក្នុងករណីការចូលរួមសិក្ខាសាលានេះ នៅមិនទាន់ស្រូបបាននូវពុទ្ធិជាចំណេះដឹង ចំណេះធ្វើបទពិសោធន៍ និងបទប្បញ្ញត្តិសម្រាប់យកទៅអនុវត្តកាតព្វកិច្ចសាពើពន្ធបានត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមាននោះសិក្ខាកាមអាចចុះឈ្មោះចូលរៀនបន្ថែម អំពីសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ បទប្បញ្ញត្តិស្ដីពីពន្ធដារ និងកិច្ចដំណើរការនៃការបង់ពន្ធ ឬប្រធានបទពាក់ព័ន្ធនៃអង្គសិក្ខាសាលានៅថ្ងៃនេះនៅសាលាជាតិពន្ធដារ។ ទន្ទឹមនឹងនេះ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា អាចទំនាក់ទំនងសួរនាំអំពីបទប្បញ្ញត្តិស្ដីពីពន្ធដារ និងកិច្ចដំណើរការនៃការបង់ពន្ធ តាមរយៈទំនាក់ទំនងសួរនាំទៅមជ្ឈមណ្ឌលផ្ដល់ព័ត៌មាន (Call Center) របស់អគ្គនាយកដ្ឋានពន្ធដារ ដោយឥតគិតថ្លៃដែលមានលេខទូរស័ព្ទ ១២៧៧ ឬ GDT Live Chat ឬ E-mail, Facebook និងការជួបពិគ្រោះផ្ទាល់ជាមួយមន្ត្រីជំនាញជាដើម។




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ